ទស្សនៈអ្នកនិពន្ធ

វ៉ុលេ២, លេខ៧, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០

# ការអភិវឌ្ឍនៅកម្ពុជា

ខ្លឹមសារដោយបណ្ឌិត ដេវីមី រ៉ាប់ផ្លៃ *
កែសម្រួល និងបកប្រែដោយបណ្ឌិត អ៊ុន លាង**

នាពេលបច្ចុប្បន្ននេះ វាងាយស្រួលណាស់ក្នុងការបោះបង់ចោលមុខវិជ្ជាទស្សនវិជ្ជា និងទ្រឹស្តីអភិវឌ្ឍន៍ ថា "វានៅលើមេឃ" មិនមានការពាក់ព័ន្ធនឹងពិភពជាក់ស្តែង។ មនុស្សភាគច្រើននឹងអះអាងថា កម្ពុជានាសហសម័យត្រូវការវិទ្យាសាស្ត្រ ត្រូវការបច្ចេកវិទ្យា និងត្រូវការបស្ចិមប្រទេសនីយកម្មច្រើនបន្ថែមទៀត ដើម្បី "តាមឲ្យទាន់" ប្រទេសអភិវឌ្ឍន៍ផ្សេងទៀត។ អង្គការអភិវឌ្ឍន៍បរទេសបាន និងកំពុងលើកកម្ពស់គំនិតនេះដោយឥតស្រាកស្រាន្ត ហើយវាក៏ត្រូវបានមនុស្សជាច្រើននៅកម្ពុជា (រួមទាំងស្ថាប័នធនាគារខួរក្បាលក្នុងស្រុក) ទទួលយកគំនិតនេះមកអនុវត្តផងដែរ។ ប៉ុន្តែ អ្វីដែលស្ថាប័នទាំងនេះមិនបានយល់នោះ គឺថា "ការអភិវឌ្ឍ" ណាក៏ដោយដែលមិនសមស្របទៅនឹងបរិបទវប្បធម៌ ប្រវត្តិសាស្ត្រ និងសង្គមកម្ពុជា មុខនឹងបរាជ័យជាក់ជាមិនខាន។ មធ្យោបាយតែមួយគត់ ដើម្បីបំបែកវដ្តនៃការអភិវឌ្ឍដែលបរាជ័យនេះ គឺត្រូវស្វែងរកធនធានបញ្ញវន្តក្នុងស្រុកនៅកម្ពុជា។ មានតែនៅពេលណាដែលប្រជាជនកម្ពុជាក្រោកឡើង ហើយពន្យល់មូលហេតុដែលគំរូ "អភិវឌ្ឍន៍" មួយចំនួន មិនឆ្លើយតបទៅនឹងបរិបទក្នុងស្រុក ឬនៅពេលដែលប្រជាជនកម្ពុជាអាចចោទសួរដេញដោលពីគំរូអភិវឌ្ឍន៍របស់បស្ចិមប្រទេស ដោយទ្រឹស្តីក្នុងស្រុករបស់ខ្លួនទេ ទើបស្ថានភាពអាចប្រសើរឡើង។ វិធីតែមួយគត់ដើម្បីបំបែកវដ្តនៃការអភិវឌ្ឍបរាជ័យនេះ គឺដំបូងបំផុតត្រូវតែមានភាពក្លាហានក្នុងការបង្កើតជំនឿថា វាមានការគិតផ្សេងទៀតដែលខុសពីរបត់បញ្ញវន្តបស្ចិមប្រទេស។

ការប៉ុនប៉ងដែលជោគជ័យណាក៏ដោយ ត្រូវតែឈរលើគ្រឹះទស្សនវិជ្ជាក្នុងស្រុក។ ប៉ុន្តែ ការព្យាយាមបង្កើតការឆ្លើយតបបែបក្នុងស្រុកចំពោះគំនិតបស្ចិមប្រទេស ដែលមិនដំណើរការនៅកម្ពុជា (ក្នុងដំណើរនៃការអភិវឌ្ឍ) ដោយគ្មានការសិក្សាស៊ីជម្រៅទៅលើគំនិតបស្ចិមប្រទេសទាំងនោះ វាគឺជាមាគ៌ាមួយដែលនាំទៅកាន់ជាតិនិយមជ្រុល និងការប្រឈមហួសហេតុ (ដូចដែលធ្លាប់បានកើតមាននៅក្នុងសម័យខ្មែរក្រហម)។ ដូចដែលទស្សនវិទូ អាល្លឺម៉ង់ លោក ហ្វ្រីឌ្រិស្ក នីឈេ បានទាមទារ យើងត្រូវតែព្យាយាមបង្កើតគុណតម្លៃថ្មី។ ការបង្កើតគុណតម្លៃថ្មីសម្រាប់កម្ពុជា ត្រូវតែចាប់ផ្តើមជាមួយការសំយោគ និងការឆ្លើយតបប្រកបដោយភាពច្នៃប្រឌិតទៅលើទស្សនវិជ្ជាបស្ចិមប្រទេស និងទ្រឹស្តីសង្គម។ នៅពេល

---

***លោកបណ្ឌិត ដេវីមី រ៉ាប់ផ្លៃ** គឺជាសាស្ត្រាចារ្យរងនៃសាកលវិទ្យាល័យក្យូតូ ប្រទេសជប៉ុន។
****លោកបណ្ឌិត អ៊ុន លាង** គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ដែលទស្សនវិជ្ជាក្នុងស្រុករបស់កម្ពុជា និងទ្រឹស្តីសង្គម ត្រូវបានបង្កើតឡើង វានឹងក្លាយទៅជាគ្រឹះសម្រាប់ការអភិវឌ្ឍនៅកម្ពុជា (ដែលផ្ទុយពីការផ្តោតទាំងស្រុងទៅលើបស្ចិមប្រទេសនីយកម្ម សម្រាប់ការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្ន)។ វាត្រូវការពេល ប៉ុន្តែដរាបណាទាល់តែទស្សនវិជ្ជាក្នុងស្រុក និងទ្រឹស្តីសង្គម កើតមានឡើងពេញលេញ ទើប "ការគិតរបស់កម្ពុជា បម្រើឲ្យកម្ពុជា"។

ក្នុងន័យទូលំទូលាយជាងនេះ ពួកយើងដែលមិនមែនជាខ្មែរត្រូវការឲ្យកម្ពុជារកសំឡេងដើមរបស់ខ្លួនឲ្យបានឆាប់ ទើបភ្នាក់ងារម្ចាស់ជំនួយឈប់និយាយជំនួសឲ្យកម្ពុជា ហើយទើបកម្ពុជាអាចរួមចំណែកបន្ទរសំឡេងព្រមគ្នាជាសាកល ក្នុងការអំពាវនាវឲ្យមានពិភពលោកមួយកាន់តែប្រកបដោយសន្តិភាព និងសមធម៌។ ដូចដែលបណ្ឌិត អ៊ុន លាង បន្តរុករក និងសួរខ្ញុំក្នុងការសន្ទនាដ៏ស៊ីជម្រៅជាច្រើនលើកច្រើនសាររបស់យើងថា "តើអ្វីទៅជាគ្រឹះស៊ីជម្រៅបំផុតនៃគោលការណ៍ទស្សនវិជ្ជាខ្មែរ "សន្តិភាវកម្ម"? តើយើងអាចយល់ពីបញ្ញត្តិ "សន្តិភាវកម្ម" នេះ ក្នុងភាសាទស្សនវិជ្ជាសហសម័យដោយរបៀបណា? ហើយថាតើវានឹងរួមចំណែកអ្វីខ្លះដល់អនាគតកម្ពុជា និងពិភពលោករួមរបស់យើង?

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 10 950 456
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center